| ឯកសារបកប្រែ |
|---|
| TRANSLATION/TRADUCTION |
| ថ្ងៃ ខែ ឆ្នាំ (Date): 31-Aug-2011, 11:35 |
| CMS/CFO: Sann Rada |

# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារនៃការដាក់ឯកសារ

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

## ចំណាត់ថ្នាក់ឯកសារ

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

# សំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំសេចក្តីណែនាំអំពីការដាក់ការឆ្លើយតប ទៅនឹងការឆ្លើយតបនានា

---

| <u>អ្នកដាក់ឯកសារ:</u> | <u>អ្នកទទួលឯកសារ:</u> | <u>ចម្លងជូន:</u> |
|---|---|---|
| សហព្រះរាជអាជ្ញា: | អង្គជំនុំជម្រះសាលាដំបូង: | ជនជាប់ចោទ: |
| លោកស្រី ជា លាង | ចៅក្រម និល ណុន, ប្រធាន | នួន ជា |
| លោក Andrew CAYLEY | ចៅក្រម Silvia CARTWRIGHT | អៀង សារី |
| | ចៅក្រម យ៉ា សុខន | អៀង ធីរិទ្ធ |
| | ចៅក្រមJean-Marc LAVERGNE | ខៀវ សំផន |
| | ចៅក្រម ធូ មណី | |
| | | |
| | សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី: | មេធាវីការពារក្តីជនជាប់ចោទ: |
| | លោក ពេជ អង្គ | លោក សុន អរុណ |
| | Elisabeth SIMONNEAU FORT | លោក Michiel PESTMAN |
| | | លោក Victor Koppe |

លោក អាង ឧត្តម
លោក Michael G.KARNAVAS
លោក ផាត់ ពៅសីាង
កញ្ញា Diana ELLIS QC
លោក ស សូវាន
លោក Jacques VERGÈS

## I. សេចក្ដីផ្ដើម

១- នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១១ មេធាវីការពារក្ដីរបស់ អៀង សារី ("មេធាវីការពារក្ដី") បានដាក់ *សេចក្ដីសង្កេតរបស់ អៀង សារី ទៅលើការឆ្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងចម្លើយតបនានារបស់មេធាវីការពារក្ដីលើសំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យកំណត់បទចោទជាថ្មីឡើងវិញក្នុងដីកាដំណោះស្រាយ និងដកលក្ខខណ្ឌតម្រូវស្ដីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីបទល្មើសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ* ("សេចក្ដីសង្កេត")[1]។ សេចក្ដីសង្កេតបានអះអាងដើម្បីកែតម្រូវនូវ "ការលើកឡើងមិនត្រឹមត្រូវ ការលើកឡើងដោយភាន់ច្រឡំ និងការកំណត់អង្គហេតុ និងអង្គច្បាប់មិនត្រឹមត្រូវមួយចំនួន"[2] ដែលបានចោទប្រកាន់នៅក្នុង*ការឆ្លើយតបរួមរបស់សហ ព្រះរាជអាជ្ញា ទៅនឹងចម្លើយតបនានារបស់មេធាវីការពារក្ដីលើសំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យកំណត់បទចោទជាថ្មីឡើងវិញក្នុងដីកាដំណោះស្រាយ និងដកលក្ខខណ្ឌតម្រូវស្ដីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីបទល្មើសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ* ("ការឆ្លើយតបរួម")[3]។

២- សហព្រះរាជអាជ្ញាសូមជូនសេចក្ដីសន្និដ្ឋានថា សេចក្ដីសង្កេតនេះជាសំខាន់បង្កើតឡើងបានជាការឆ្លើយតបមួយទៅនឹងការឆ្លើយតបរួមនោះ ហើយវាពុំមានមូលដ្ឋានណាមួយនៅក្នុងវិធានផ្ទៃក្នុងឡើយ ("វិធាន")[4] ឬក៏មិនមាននៅក្នុង*សេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារនៅចំពោះមុខ អវតក* ដែរ ("សេចក្ដីណែនាំអនុវត្ត")[5]។ អាស្រ័យហេតុដូច្នេះ សហព្រះរាជអាជ្ញាសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងចេញនូវគោលការណ៍ណែនាំមួយដោយមានការបញ្ជាក់ថា គេមិនអនុញ្ញាតឲ្យភាគីនានា ដាក់ការឆ្លើយតបទៅនឹងការឆ្លើយតបនានា ដោយគ្មានការស្នើសុំការអនុញ្ញាតពីអង្គជំនុំជម្រះទេ និងធ្វើការកំណត់អត្ថសញ្ញាណអំពីកាលៈទេសៈដែលគេអនុញ្ញាតឲ្យមានការស្នើសុំបែបដូច្នោះ។

## II. អំណះអំណាង

[1] **E95/7**, សេចក្ដីសង្កេត, ថ្ងៃទី១៨ សីហា ២០១១, លេខERN 00725884-93 ។

[2] *ដដែលដូចមុន* ។

[3] **E95/6**, ការឆ្លើយតបរួម, ថ្ងៃទី១១ សីហា ២០១១, លេខERN 00725270-307 ។

[4] វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៨), ដូចបានធ្វើវិសោធនកម្មនៅថ្ងៃទី៣ សីហា ២០១១ ។

[5] សេចក្ដីណែនាំអនុវត្ត (វិសោធនកម្មលើកទី ៧), ដូចបានធ្វើវិសោធនកម្មនៅថ្ងៃទី១៧ សីហា ២០១១ ។

## ក. សេចក្តីសង្កេត បង្កើតបានជាការឆ្លើយតបមួយ ទៅនឹងការឆ្លើយតបរួម ហើយតាមវិធានផ្ទៃក្នុង ឬ សេចក្តីណែនាំអនុវត្ត គេមិនអនុញ្ញាតទេ

៣- ដោយហេតុថាវាមានការច្បាស់លាស់នៅនឹងក្របខាងមុខនៃឯកសារហើយថា សេចក្តីសង្កេតបង្កើតបានជាការឆ្លើយតបមួយទៅនឹងការឆ្លើយតបរួម។ សេចក្តីសង្កេតបានលើកឡើងដោយ ត្រង់ៗចំចំណុចទាំងឡាយដែលបានលើកឡើងនៅក្នុងការឆ្លើយតបរួម។ ហេតុដូច្នេះហើយគេអាចធ្វើចំណាត់ថ្នាក់របស់វាថាជាការឆ្លើយតបមួយទៅនឹងការឆ្លើយតបតែប៉ុណ្ណោះ ដោយមិនគិតអំពីចំណងជើងឯកសារនោះឡើយ។

៤- មិនថាគេបានដាក់ចំណងជើង ឬបានពិពណ៌នាអំពីឯកសារនោះថាយ៉ាងដូចម្តេចនោះទេ ការដាក់ការឆ្លើយតបទៅនឹងការឆ្លើយតបរួម មិនមានមូលដ្ឋាននៅក្នុងវិធាន ឬនៅក្នុងសេចក្តីណែនាំអនុវត្តនោះឡើយ។ វិធាន៩២ បានអនុញ្ញាតឲ្យភាគីនានាធ្វើសារណាជាលាយលក្ខណ៍អក្សរ “តាមរបៀបដែលមានចែងនៅក្នុងសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ”។ ពេលដែលចែងនៅក្នុងសេចក្តីណែនាំអនុវត្តមាត្រា៨ បានសរសេរពីវិធាននានាទាក់ទងទៅនឹងការដាក់ឯកសារស្តីពីចម្លើយតប និងការឆ្លើយតប ទៅនឹងសារណា និងពាក្យស្នើសុំ។ ជាពិសេស មាត្រា៨.៣ បានចែងពីបទប្បញ្ញត្តិសម្រាប់ភាគីនានាដាក់ចម្លើយតបទៅនឹងសារណា ឬពាក្យស្នើសុំនៅក្នុងរយៈពេលចំនួនដប់(១០)ថ្ងៃគិតពីថ្ងៃដាក់ឯកសារចុងក្រោយនេះ។ មាត្រា៨.៤ បានចែងអំពីការកម្រិតសិទ្ធិក្នុងការឆ្លើយតប ដោយបានចែងថា “ការឆ្លើយតបទៅនឹងសារណាតប ត្រូវបានអនុញ្ញាតតែក្នុងករណី ដែលមិនមានការស្នើសុំឲ្យមានការដេញដោលដោយផ្ទាល់មាត់ប៉ុណ្ណោះ” ហើយបានកំណត់រយៈពេលចំនួនប្រាំ(៥)ថ្ងៃសម្រាប់ធ្វើការដាក់ឯកសារបែបដូច្នេះ[6]។

៥- នៅក្នុងសេចក្តីណែនាំមួយ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់អំពីការអនុវត្តនូវសេចក្តីណែនាំអនុវត្តនេះពាក់ព័ន្ធទៅនឹងការឆ្លើយតបនានា ដោយបានថ្លែងថា “ការឆ្លើយតបទៅនឹងចម្លើយតប ត្រូវបានពិចារណាតែនៅពេលដែលការឆ្លើយតបនោះពាក់ព័ន្ធទៅនឹងបញ្ហាដែល

[6] មាត្រា ៨.៣ និង ៨.៤ មានទម្រង់ដូចគ្នាបេះបិទទៅនឹងសំណៅពីមុននៃសេចក្តីណែនាំអនុវត្ត (វិសោធនកម្មលើកទី ៦), ដែលនៅជាធរមានរហូតដល់ថ្ងៃទី១៦ សីហា ២០១១ ។

ត្រូវពិភាក្សាដេញដោយដោយផ្ទាល់មាត់ និងជាជម្រើសមួយជំនួសឲ្យការពិភាក្សាដេញដោយដោយផ្ទាល់មាត់" ហើយថា "អង្គជំនុំជម្រះពិចារណាឃើញថា អង្គជំនុំជម្រះមានឆន្ទានុសិទ្ធិ ក្នុងការសម្រេចថាតើពេលណាការឆ្លើយតបទៅនឹងចម្លើយតបត្រូវតម្រូវឲ្យមាន"[7]។

៦- ទាំងសេចក្តីណែនាំអនុវត្ត និងទាំងសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង មិនបានពិចារណាអំពីការដាក់ការឆ្លើយតបទៅនឹងការឆ្លើយតបទេ។ បើសិនជាគេអនុញ្ញាតឲ្យមានសិទ្ធិក្នុងការឆ្លើយតបមួយនេះបន្ថែមទៀត នោះវាមុខជានឹងត្រូវបានលើកឡើងនៅក្នុងសេចក្តីណែនាំអនុវត្ត ឬនៅក្នុងសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងជាមិនខាន។ តាមការពិត ឲ្យតែមានការបញ្ជាក់ពីអង្គជំនុំជម្រះសាលាដំបូងថា សិទ្ធិក្នុងការឆ្លើយតបទៅនឹងការឆ្លើយតប គឺជាសិទ្ធិមួយ ដែលបានកម្រិតដោយខ្លួនឯងនោះ គេអាចសន្និដ្ឋានបានថាការដាក់ឯកសារណាមួយក៏ដោយដែលជាការឆ្លើយតបទៅនឹងការឆ្លើយតបនោះ គឺពិតជាមិនត្រូវបានគេអនុញ្ញាតឲ្យមាននោះឡើយ។

### ខ. សហព្រះរាជអាជ្ញា ពីមុនមកមិនដែលបានដាក់ការឆ្លើយតបទៅនឹងការឆ្លើយតបនានាទេ ហើយក៏មិនមានការអនុវត្តដែលគេទទួលយកបានណាមួយស្តីពីការអនុញ្ញាតឲ្យដាក់ឯកសារបែបដូច្នេះដែរ

៧- សេចក្តីសង្កេតបានកត់សម្គាល់ថា "អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានទទួលយក និងដាក់សេចក្តីសន្និដ្ឋាននានារបស់ ក.ស.ព ទៅក្នុងសំណុំរឿងរួចហើយ"[8] ហើយបានរៀបរាប់នូវការដាក់ឯកសារពីមុនៗចំនួនបី(៣)ដោយសហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់មេធាវីការពារក្តីទាក់ទងទៅនឹងកាលបរិច្ឆេទកំណត់[9] ក៏ដូចជាទៅនឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែរ[10]។ ដោយការសន្មតទុកជាមុន ការយោងទៅដល់ការដាក់ឯកសារពីមុនៗចំនួនបី(៣)របស់សហព្រះរាជអាជ្ញា គឺមានបំណង

---

[7] **E64**, សេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងសារណាតប, ការឆ្លើយតបទៅនឹងសារណាតប និងការដាក់ឯកសារតែមួយភាសានៅក្នុង ករណីពិសេស (មាត្រា៧.២, មាត្រា៨.៣ និង មាត្រា៨.៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក ដែលត្រូវបាន ធ្វើវិសោធនកម្ម), ថ្ងៃទី១០ មីនា ២០១១, លេខERN 00650894-5 ។

[8] **E95/7**, សេចក្តីសង្កេត, ដូចកំណត់សម្គាល់លេខ ៣ និង អមទៅដោយអត្ថបទ ។

[9] **E14/1**, សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាលើសំណើបន្ទាន់របស់មេធាវីការពារក្តីរបស់ អៀង ធីរិទ្ធ និង នួន ជា សុំឲ្យបញ្ជាក់ថ្ងៃផុតកំណត់, ថ្ងៃទី២៦ មករា ២០១១, លេខERN 00640189-93 ។ **E24/1**, សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញាលើសំណើរបស់ អៀង ធីរិទ្ធ ស្នើសុំឲ្យមានការបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់អញ្ញត្រកម្ម, ថ្ងៃទី៣១ មករា ២០១១, លេខERN 00641065-8 ។

[10] **E23/1**, សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញាទៅលើញត្តិរបស់ អៀង សារី សុំការណែនាំអំពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី, ថ្ងៃទី៤ កុម្ភៈ ២០១១, លេខERN 00641748-50 ។

គាំទ្រដល់សិទ្ធិរបស់មេធាវីការពារក្ដីក្នុងការដាក់សេចក្ដីសង្កេត ដោយផ្អែកទៅលើ "សមភាពក្នុងការតទល់ក្ដី" ឬក៏ផ្អែកទៅលើ "ការអនុវត្តដែលបានទទួលយក"។

៨- យ៉ាងណាក៏ដោយ ការដាក់ឯកសារពីមុនៗចំនួនបី(៣)ដោយសហព្រះរាជអាជ្ញា មិនអាចប្រៀបធៀបឱ្យស្មើបានទៅនឹងសេចក្ដីសង្កេតឡើយ។ ខណៈដែលការដាក់ឯកសារពីមុនៗ អាចត្រូវបានគេដាក់ចំណងជើងថា "សេចក្ដីសង្កេត" នោះវាជាការមួយច្បាស់លាស់ណាស់ដែលលេចចេញពីខ្លឹមសាររបស់វា ដែលបានបង្កើតបានជាចម្លើយតបទីមួយរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើក្នុងបញ្ហានេះ របស់មេធាវីការពារក្ដី។ ដូច្នេះ ការដាក់ឯកសារពីមុនៗត្រូវបានធ្វើឡើង ដោយស្របទៅតាមមាត្រា៨.៣ នៃសេចក្ដីណែនាំអនុវត្ត ដែលនៅក្នុងរយៈពេលវេលាពាក់ព័ន្ធដែលបានអនុញ្ញាត (ដូចដែលនៅតែបានអនុញ្ញាត) ភាគីនានាដែលមានសិទ្ធិធ្វើសារណាតបទៅនឹងសារណា និងពាក្យស្នើសុំនានា។ អង្គហេតុពិតដែលថា ការដាក់ឯកសារពីមុនៗ ត្រូវបានគេដាក់ចំណងជើងថាជា "សេចក្ដីសង្កេត" គឺមិនពាក់ព័ន្ធជាមួយនឹងចរិតលក្ខណៈពិតនៃការដាក់ឯកសារ ឬមួយក៏មិនពាក់ព័ន្ធជាមួយនឹងសិទ្ធិរបស់សហព្រះរាជអាជ្ញាក្នុងការដាក់ឯកសារទាំងនោះទេ។ អាស្រ័យហេតុដូច្នេះ គេមិនអាចផ្ដល់សំអាងបានថា ពីមុនមកអង្គជំនុំជម្រះសាលាដំបូងធ្លាប់បានបន្ទយការដាក់ឯកសារនានារបស់សហព្រះរាជអាជ្ញា ដែលមានចរិតលក្ខណៈស្រដៀងគ្នាទៅនឹងសេចក្ដីសង្កេតនាពេលបច្ចុប្បន្ននេះ ហើយឥឡូវនេះគេត្រូវតែពន្លាតនូវការផ្ដល់នូវសិទ្ធិស្រដៀងគ្នាមួយនេះទៅដល់មេធាវីការពារក្ដីផងដែរ។ ដូចគ្នានេះដែរ សហព្រះរាជអាជ្ញាមិនមានលទ្ធភាពធ្វើការ កំណត់អត្តសញ្ញាណពីកាលៈទេសៈដទៃទៀតណាមួយ ដែលភាគីមួយដាក់ឯកសារមួយដែលជាការឆ្លើយតបទៅនឹងការឆ្លើយតបមួយ នោះការដាក់ការឆ្លើយតបទៅនឹងការឆ្លើយតបទាំងនោះ ឥឡូវនេះអាចត្រូវគេនិយាយបានថាជា "ការអនុវត្តមួយដែលគេបានទទួលយក" នៅអវតក។

## គ. មិនមានការស្នើសុំការអនុញ្ញាតណាមួយដែលគេបានស្វែងរកពី ឬក៏មិនមានការអនុញ្ញាតណាមួយដែលបានសម្រេចដោយអង្គជំនុំជម្រះសាលាដំបូងទេ

៩- ការធ្វើយុត្តិកម្មទៅលើសេចក្ដីសង្កេតដែលបានលើកឡើងមកនេះ គឺថាការឆ្លើយតបរួមនោះមាន "ការលើកឡើងមិនត្រឹមត្រូវ ការលើកឡើងដោយភាន់ច្រឡំ និងការកំណត់អង្គហេតុ និងអង្គច្បាប់ មិនត្រឹមត្រូវ" ដែលគេត្រូវតែជម្រាបជូនដល់អង្គជំនុំជម្រះសាលាដំបូង។ ដូចដែលបានលើកឡើងបន្តទៀតនៅ

ខាងក្រោមនេះ ការចោទប្រកាន់ថាការឆ្លើយតបរួមមាន "ការលើកឡើងមិនត្រឹមត្រូវ ការលើកឡើងដោយភាន់ច្រឡំ និងការកំណត់អង្គហេតុនិងអង្គច្បាប់មិនត្រឹមត្រូវ" គឺមិនមានមូលដ្ឋានទេ។ យ៉ាងដូច្នេះក៏ដោយ សូម្បីតែថាបើសិនពិតមែននោះ ការណ៍នេះនឹងមិនមានធ្វើយុត្តិកម្មដល់ការដាក់ការឆ្លើយតបមួយទៅនឹងការឆ្លើយតបរួមនោះដែលពុំមានការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូងទេ។

១០- សហព្រះរាជអាជ្ញាទទួលស្គាល់ថា អង្គជំនុំជម្រះសាលាដំបូងអាចនឹងមានឆន្ទានុសិទ្ធិក្នុងការអនុញ្ញាតឱ្យភាគីនានាដាក់សារណាជាលាយលក្ខណ៍អក្សរដែលវិធាន ឬសេចក្ដីណែនាំអនុវត្តមិនបានពិចារណានៅក្នុងកាលៈទេសៈលើកលែងនានាទេ។ យ៉ាងនេះក៏ដោយ នៅក្នុងរឿងក្ដីបច្ចុប្បន្ននេះ អង្គជំនុំជម្រះសាលាដំបូងមិនបានអនុញ្ញាតឱ្យមេធាវីការពារក្ដីដាក់ជូនទូវសេចក្ដីសង្កេតទេ។ ជាការពិតហើយ មេធាវីការពារក្ដីមិនបានស្វែងរកការស្នើសុំការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូង ដើម្បីដាក់សេចក្ដីសង្កេតទេ។ ផ្ទុយទៅវិញ មេធាវីការពារក្ដីបានបន្តដំណើរកិច្ចនីតិវិធី ដោយផ្អែកលើមូលដ្ឋានដែលថា គេបានដាក់ចំណងជើងវាថាជាសេចក្ដីសង្កេត ដោយបានថ្លែងថា សេចក្ដីសង្កេតគឺ "ចាំបាច់" និង "ស្ថិតនៅក្នុងផលប្រយោជន៍នៃយុត្តិធម៌"។

១១- វិធីសាស្ត្រដែលមេធាវីការពារក្ដីបានប្រកាន់យកនៅក្នុងការដាក់សេចក្ដីសង្កេត គឺផ្ទុយគ្នាទៅនឹងវិធីសាស្ត្រ ដែលគាត់បានប្រកាន់យកនៅក្នុងការដាក់ការឆ្លើយតបទៅនឹងសារណាតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា។ ការឆ្លើយតបនេះ ត្រូវបានដាក់នៅថ្ងៃទី១ ខែសីហា ឆ្នាំ២០១១ ជាមួយគ្នានឹងសំណើជាក់លាក់មួយ ស្នើសុំការអនុញ្ញាតធ្វើការឆ្លើយតប ឬមួយម្យ៉ាងវិញទៀតស្នើសុំឱ្យមានសវនាការដេញដោលដោយផ្ទាល់មាត់[11]។ យ៉ាងណាក៏ដោយ គេបានកត់សម្គាល់ថា ដោយហេតុថាការឆ្លើយតបត្រូវបានភ្ជាប់ទៅនឹងការស្នើសុំការអនុញ្ញាតឆ្លើយតបនោះ ត្រូវបានដាក់ចូលទៅក្នុងផ្នែកសាធារណៈនៃសំណុំរឿងនៅពេលជាមួយ គ្នានឹងពេលឆ្លើយតប ទោះបីជានៅមិនទាន់មានការសម្រេចលើសំណើសុំត្រូវបានធ្វើឡើង ដោយអង្គជំនុំជម្រះសាលាដំបូងក៏ដោយ។ សហព្រះរាជអាជ្ញាសូមជូនសេចក្ដីសន្និដ្ឋានថា ការណ៍នេះបានធ្វើឱ្យគោលបំណងនៃសំណើសុំការអនុញ្ញាតទទួលបរាជ័យ ហើយថានីតិវិធីដ៏ត្រឹមត្រូវ នោះគឺការអនុញ្ញាតឱ្យដាក់ការឆ្លើយតបនៅមុនពេល និងដោយឡែកពីការឆ្លើយតបពិតប្រាកដ។

---

[11] **E99/1/1**, សំណើរបស់ អៀង សារី សុំអនុញ្ញាតឆ្លើយតប ឬ សុំឱ្យមានសវនាការផ្ទាល់មាត់ និង ការឆ្លើយតបទៅនឹង "ចម្លើយតប" របស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យកំណត់បទចោទសាជាថ្មីទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, ថ្ងៃទី១ សីហា ២០១១, លេខERN 00721466-73 ។

១២- នៅក្នុងករណីបច្ចុប្បន្ននេះ ការសន្មតរបស់មេធាវីការពារក្តីពីសិទ្ធិរបស់ខ្លួនក្នុងការដាក់សេចក្តីសង្ខេប ដោយគ្មានសូម្បីតែការអះអាងណាមួយក៏គ្មានដែរ ដើម្បីសុំការអនុញ្ញាតនោះ បានធ្វើឱ្យអន្តរាយដល់សិទ្ធិអំណាចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការកំណត់ថាតើត្រូវទទួលយកសារណាជាលាយលក្ខណ៍អក្សរដែលមិនបានគ្រប់ដណ្តប់យ៉ាងជាក់លាក់ដោយសេចក្តីណែនាំអនុវត្តដែរ ឬទេ។

## ឃ. មិនមានអត្ថិភាពនៃកាលៈទេសៈពិសេសសម្រាប់ធ្វើយុត្តិកម្មចំពោះការអនុញ្ញាតឱ្យដាក់សេចក្តីសង្ខេបផ្សេងៗនោះឡើយ ទោះជានៅក្នុងករណីណាក៏ដោយ

១៣- ទោះបីជាមានការស្នើសុំការអនុញ្ញាតពីមេធាវីការពារក្តី ដើម្បីដាក់ជូននូវសេចក្តីសង្ខេបផ្សេងៗនោះក៏ដោយក៏ "សេចក្តីថ្លែងដែលខុស សេចក្តីថ្លែងដែលធ្វើឱ្យយល់ច្រឡំ និងការកំណត់បទចោទដែលខុសខាងអង្គហេតុ និងអង្គច្បាប់" នឹងមិនមានមូលដ្ឋានគ្រប់គ្រាន់ ដើម្បីឱ្យផ្តល់ជូននូវការអនុញ្ញាតបានដែរ។

១៤- សេចក្តីថ្លែងនានានៅក្នុងចម្លើយតបរួម ដែលត្រូវបានលើកយកមកធ្វើជាបញ្ហានៅក្នុងសេចក្តីសង្ខេបនោះមិនអាចត្រូវបានកំណត់ដោយត្រឹមត្រូវថាជា "សេចក្តីថ្លែងដែលខុស" "សេចក្តីថ្លែងដែលធ្វើឱ្យយល់ច្រឡំ" ឬ "ការកំណត់បទចោទដែលខុស" បានឡើយ។ ផ្ទុយទៅវិញ សេចក្តីថ្លែងទាំងនេះ គឺជាការបកស្រាយស្របតាមច្បាប់របស់សហព្រះរាជអាជ្ញាអំពីបញ្ហានានាខាងអង្គច្បាប់ និងខាងអង្គហេតុដែលទាក់ទងទៅនឹងបញ្ហាដែលលមានសារៈសំខាន់ទាំងឡាយ នៅក្នុងទំនាស់រវាងភាគីនានា។

១៥- បញ្ហាទាំងឡាយនៅក្នុងទំនាស់ដែលលេចចេញពីសំណើសុំចំនួនបីរបស់សហព្រះរាជអាជ្ញាដែលបានដាក់កាលពីខែមិថុនា ឆ្នាំ២០១១៖ *សំណើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងដកចេញនូវលក្ខខណ្ឌតម្រូវអំពីទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ*[12] ។ *សំណើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងកំណត់បទចោទជាថ្មីឡើងវិញលើអង្គហេតុនានា ដែលង្ហាញសក្ខីកម្មអំពីការប្រព្រឹត្តិបទរំលោភសេពសន្ថវៈ ដោយចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងបទរំលោភសេពសន្ថវៈវិញ ជាជាងចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងបទអំពើអមនុស្សធម៌*

[12] **E95** សំណើសុំទាក់ទងនឹងជម្លោះប្រដាប់អាវុធ, ១៥ មិថុនា ២០១១, ERN 00716026-37 ។

*ផ្សេងទៀត[13]។ និងសំណើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកថា សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី៣ (JCE III) ថាជាទម្រង់នៃការទទួលខុសត្រូវមួយទៀតដែលជំនួស[14] ("សំណើសុំ"ជាសមូហភាព)។* អនុលោមតាមការអនុវត្តដែលជាបទដ្ឋាន មេធាវីការពារក្តីមានឱកាសក្នុងការដាក់ចម្លើយតបនានាទៅនឹងសំណើសុំនីមួយៗក្នុងចំណោមសំណើសុំទាំងនេះ ហើយជាក់ស្តែងគឺបានធ្វើដូច្នេះរួចហើយកាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១[15]។ សហព្រះរាជអាជ្ញា ដោយអនុលោមតាមការណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង[16] បានដាក់នូវការឆ្លើយតបរួមរបស់ខ្លួនទៅនឹងសារណាឆ្លើយតបរបស់មេធាវីការពារក្តីនានា (បន្ថែមពីលើចម្លើយតបរបស់ក្រុមមេធាវីការពារក្តីផ្សេងៗទៀត)។ នៅការឆ្លើយតបរួមនេះមិនបានលើកឡើងពីបញ្ហាដែលមានសារៈសំខាន់ថ្មីៗដែលកាលពីមុនមកមេធាវីការពារក្តីមិនមានឱកាសធ្វើការឆ្លើយតបនោះឡើយ។ ហេតុដូចនេះ ក្នុងពេលឥឡូវនេះមេធាវីការពារក្តីមិនអាចបើកការជជែកតវ៉ាគ្នាសាជាថ្មីម្តងទៀតលើបញ្ហានានាដែលកំពុងមានទំនាស់ដែលកើតចេញមកពីសំណើទាំងនេះ ក្រោមរូបភាពនៃការកែតម្រូវលើ"សេចក្តីថ្លែងដែលខុស សេចក្តីថ្លែងដែលធ្វើឱ្យយល់ច្រឡំ និងការកំណត់បទចោទដែលខុសខាងអង្គហេតុ និងអង្គច្បាប់" ដែលមាននៅក្នុងចម្លើយតបរួមនោះបានឡើយ។

១៦-នេះគឺជាទិដ្ឋភាពជាមូលដ្ឋានគ្រឹះមួយនៃដំណើការរឿងក្តីក្នុងពេលបច្ចុប្បន្ននេះ ដែលភាគីនានានឹងមានទស្សនៈយល់ឃើញខុសៗគ្នាទៅលើបញ្ហាដែលមានសារៈសំខាន់នានា ដែលស្ថិតនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ បញ្ហាទាំងឡាយដែលស្ថិតនៅក្នុងទំនាស់រវាងភាគីនានា តាមធម្មតាគឺនឹងត្រូវបានយកមកជជែកតវ៉ាគ្នា ដោយផ្អែកលើមូលដ្ឋាននៃការបកស្រាយខាងអង្គហេតុ និងអង្គច្បាប់ដោយមានការប្រកួតប្រជែងគ្នា។ ការបកស្រាយទាំងឡាយបែបនេះ គឺទាក់ទងនឹងរឿងដាក់សារណា ដែលជាសិទ្ធិដ៏ត្រឹមត្រូវរបស់ភាគីនីមួយៗត្រូវធ្វើនៅក្នុងរង្វង់នៃការកំរិតព្រំដែនដែលវិធានផ្ទៃក្នុង និងសេចក្តីណែនាំ

[13] **E99** សំណើសុំទាក់ទងនឹងអំពើរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, ១៦ មិថុនា ២០១១, ERN 00708301-15 ។

[14] **E100** សំណើសុំទាក់ទងនឹងសហកម្មឧក្រិដ្ឋកម្មរួម III (JCE III), ១៧ មិថុនា ២០១១, ERN 00708242-56 ។

[15] **E95/4** ចម្លើយតបរបស់ អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ស្នើឱ្យអង្គជំនុំជម្រះសាលាដំបូង ដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ & សំណើសុំឱ្យមានសវនាការផ្ទាល់មាត់, ២២ កក្កដា ២០១១, ERN 00716010-25 ។ **E99/4** ចម្លើយតបរបស់ អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យអង្គជំនុំជម្រះសាលាដំបូង កំណត់បទចោទសាជាថ្មីទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗទៀត និងសំណើសុំឱ្យមានសវនាការផ្ទាល់មាត់, ២២ កក្កដា ២០១១, ERN 00716026-37 ។ **E100/2** ចម្លើយតបរបស់ អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ចាត់ទុកសហកម្មឧក្រិដ្ឋកម្មរួមទីបី(JCE III) ជាទម្រង់មួយទៀតនៃការទទួលខុសត្រូវ និងសំណើសុំឱ្យមានសវនាការផ្ទាល់មាត់, ២២ កក្កដា ២០១១, ERN 00719826-41 ។

[16] **E107** សេចក្តីសម្រេចស្តីពីការពន្យារពេលកំណត់, ៧ កក្កដា ២០១១, ERN 00711953-4 ។ **E107/3** សេចក្តីសម្រេចលើសំណើសុំពន្យារពេលកំណត់របស់សហព្រះរាជអាជ្ញា, ២ សីហា ២០១១, ERN 00721799-801 ។

អនុវត្តបានអនុញ្ញាតឱ្យ។ សិទ្ធិដែលមានជាប់មកជាមួយស្រាប់របស់ភាគីនីមួយៗក្នុងការដាក់សារណា គឺជាសិទ្ធិក្នុងការបញ្ចេញនូវវោហារស័ព្ទក្នុងការបកស្រាយច្បាប់ ឬការយោងទៅលើផ្នែកណាមួយនៃឯកសារផ្សេងៗទៀត ក្នុងគោលបំណងគាំទ្រដល់ជំហរតែមួយគត់របស់ខ្លួន ដោយមិនចាំបាច់បង្ហាញអំពីបរិបទណាមួយដែលអំណោយផលទៅដល់ភាគីបដិបក្ខផងដែរនោះទេ។ ការខកខានមិនបានដាក់បញ្ចូលនូវបរិបទមួយបែបនេះ គឺមិនត្រូវបានចាត់ទុកថាជា "សេចក្តីថ្លែងដែលខុស សេចក្តីថ្លែងដែលធ្វើឱ្យយល់ច្រឡំ និងការកំណត់បទចោទដែលខុសខាងអង្គហេតុ និងអង្គច្បាប់" ដូចដែលមេធាវីការពារក្តីធ្វើការតវ៉ាជំទាស់នៅក្នុងករណីរឿងក្តីនេះឡើយ។ សិទ្ធិរបស់ភាគីនីមួយៗក្នុងការដាក់សារណារបស់ខ្លួនផ្ទាល់ គឺជាការរំពឹងទុកអំពីវិធីសាស្ត្រនេះ ហើយដែលនឹងចែងពីបរិបទដែលមានការថ្លឹងថ្លែងមួយអំពីការបកស្រាយដោយប្រកួតប្រជែងគ្នា ដែលត្រូវបង្ហាញជូន។

១៧-គឺជាតួនាទីរបស់អង្គជំនុំជម្រះសាលាដំបូង ដែលត្រូវពិនិត្យពិចារណាទៅលើសារណារបស់ភាគីនានា និងដែលត្រូវបញ្ជាក់ឱ្យបានច្បាស់អំពីការបកស្រាយដែលត្រឹមត្រូវលើបញ្ហាខាងអង្គច្បាប់ និងខាងអង្គហេតុដែលទាក់ទងទៅនឹងបញ្ហាដែលមានទំនាស់នេះ។ ដោយសន្មតថា ដូចជាករណីដែលទាក់ទងនឹងសារណាឆ្លើយតបរួម សារណារបស់ភាគីទាំងឡាយត្រូវបានលើកយកមកធ្វើជាសំអាងយ៉ាងត្រឹមត្រូវ ដោយយោងទៅលើប្រភពនៃឯកសារជាដើមអាទិ៍ណាមួយ ហើយ(ទោះជាដោយចេតនាក្តី ឬដោយការធ្វេសប្រហែសក្តី) គឺមិនមានការភាន់ច្រឡំខាងអង្គហេតុ ឬខាងអង្គច្បាប់ដោយជាក់ស្តែងនៅក្នុងនោះ ដែលមានអានុភាព ឬទំនងជាមានអានុភាពក្នុងការធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំឡើយ អង្គជំនុំជម្រះសាលដំបូងត្រូវបានដាក់ឱ្យស្ថិតនៅត្រង់ទីកន្លែងយ៉ាងត្រឹមត្រូវឥតខ្ចោះ ដើម្បីឱ្យធ្វើការវិភាគ និងធ្វើសេចក្តីសម្រេចទៅលើសារណាដែលមានលក្ខណៈប្រកួតប្រជែងគ្នាទាំងនេះ។ ក្នុងការធ្វើដូចនេះ អង្គជំនុំជម្រះក៏អាចទាញយកបានផងដែរ ដោយផ្អែកលើចំណេះដឹងយ៉ាងពេញលេញរបស់ខ្លួនអំពីបរិបទនៃដំណើរការរឿងក្តីរហូតមកទល់ពេលបច្ចុប្បន្ននេះ។

១៨-សហព្រះរាជអាជ្ញាសូមលើកជូនជាយោបល់ថា ការអនុញ្ញាតដើម្បីឱ្យធ្វើសារណាតបទៅនឹងការឆ្លើយតបនានា គួរតែបានផ្តល់ឱ្យតែនៅក្នុងករណីពិសេសតែប៉ុណ្ណោះបានហើយ ដូចជាករណី បើសិនជាមានការភាន់ច្រឡំណាមួយខាងអង្គហេតុ និងខាងអង្គច្បាប់ដោយជាក់ស្តែង ដែលធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងខ្លួនឯងមិនអាចធ្វើការវាយតម្លៃបានដោយសមស្រប ឬក្នុងនៅករណី បើសិនជាការឆ្លើយតបនោះមានលើកឡើងអំពីបញ្ហាដែលមានសារៈសំខាន់ថ្មី។

១៩- ក្នុងករណីនេះ គួរកត់សំគាល់ថា នៅឯតុលាការអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) ការធ្វើសារណាឆ្លើយតបទៅនឹងការឆ្លើយតបនានាមិនត្រូវបានគេអនុញ្ញាតឲ្យធ្វើឡើយ ដូចជាករណីស្តីពីសិទ្ធិ និងការអនុវត្ត គឺត្រូវបានគេផ្តល់ការអនុញ្ញាតឲ្យដាក់សារណាឆ្លើយតបជាបន្តទៅទៀតតែក្នុងករណីដែលនៅក្នុងការឆ្លើយតបកាលពីដំបូងមានលើកឡើងអំពីបញ្ហាថ្មីណាមួយតែប៉ុណ្ណោះ។ *នៅក្នុងករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Kvočka*[17] អង្គជំនុំជម្រះសាលាឧទ្ធរណ៍ត្រូវកំណត់សម្រេចអំពីថាសំណើមួយរបស់អយ្យការដែលសុំដាក់ការឆ្លើយតបទៅនឹងសារណាឆ្លើយតបមួយរបស់ខាងមេធាវីការពារក្តី។ ដំបូងបំផុតគឺអង្គជំនុំជម្រះសាលាឧទ្ធរណ៍ធ្វើការពិនិត្យអំពីបទដ្ឋានសមស្របដែលអនុញ្ញាតក្នុងការឆ្លើយតបទៅនឹងសារណាឆ្លើយតបនានា ដោយថ្លែងថា៖

> *ជាធម្មតាការអនុញ្ញាតនឹងត្រូវបានផ្តល់ជូនដើម្បីដាក់ចម្លើយតបណាមួយជាបន្តបន្ទាប់ទៅទៀត ក្នុងករណីដែលនៅក្នុងសារណាឆ្លើយតបនោះមានលើកឡើងអំពីបញ្ហាថ្មីណាមួយ។ គឺវាមិនគ្រប់គ្រាន់ទេដែលបញ្ហាណាមួយដែលបានលើកឡើងនៅក្នុងសារណាឆ្លើយតបអាចគ្រាន់តែ "អំពាវនាវ"ឲ្យធ្វើការឆ្លើយតបតែប៉ុណ្ណោះ (ឬសមស្របជាងនេះទៀត ឲ្យធ្វើចម្លើយតបមួយជាបន្តបន្ទាប់ទៅទៀត)។ អ្នកឆ្លើយតបណាម្នាក់ ដែលនៅក្នុងចម្លើយតបរបស់គេទៅនឹងសារណា ត្រូវតែផ្តល់នូវចម្លើយរបស់ខ្លួនឲ្យបានពេញលេញលើបញ្ហាដែលបានលើកឡើងនៅក្នុងសារណានោះ ហើយលើកលែងតែក្នុងករណីដែលផលប្រយោជន៍នៃយុត្តិធម៌បានតម្រូវឲ្យធ្វើតែប៉ុណ្ណោះ គឺអ្នកឆ្លើយតបនោះមិនអាចត្រូវបានអនុញ្ញាតផ្តល់ឱកាសឲ្យធ្វើការឆ្លើយតបជាបន្តបន្ទាប់ទៀត ឬឲ្យធ្វើការរៀបរាប់លំអិតថែមទៀតពីលើចម្លើយដែលបានផ្តល់ជូនរួចហើយទៅលើបញ្ហាទាំងនោះឡើយ*[18] ។

---

[17] *រដ្ឋអាជ្ញា ទល់នឹង Miroslav Kvočka នឹងគូកន*, សំណុំរឿងលេខៈ IT-98-30/1-A, សាលដីកាលើពាក្យសុំធ្វើឡើដោយការិយាល័យអយ្យការ សុំអនុញ្ញាតដាក់ចម្លើយតបបន្ថែម (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ៦ មិថុនា ២០០២ ។

[18] *ក្នុងឯកសារដដែលដូចខាងលើ,* ត្រង់កថាខ័ណ្ឌទី២ (លើកយោងករណី *រដ្ឋអាជ្ញា ទល់នឹង Sainović និង Ojdanić*, សណុំរឿងលេខ IT-99-37-AR65, សាលដីកាស្តីពីការដោះលែងជាបណ្តោះអាសន្ន (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ៣០ តុលា ២០០២, កថាខ័ណ្ឌទី៥; និង *រដ្ឋអាជ្ញា ទល់នឹង Strugar និងគូកន,* សំណុំរឿងលេខៈ IT-01-42-AR72, សាលដីកាលើ "ពាក្យសុំរបស់ការិយាល័យអយ្យការ សុំអនុញ្ញាតដាក់ការឆ្លើយតបទៅនឹងការឆ្លើយតបរបស់មេធាវីការពារក្តី ទៅនឹងចម្លើយតបរបស់ការិយាល័យអយ្យការទៅនឹងសារណារបស់មេធាវីការពារក្តី លើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំស្តីពីយុត្តាធិការ (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ១២ កញ្ញា ២០០២, ទំព័រ២ ។

២០- ដោយផ្អែកលើមូលដ្ឋាននៃបទដ្ឋាននេះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានផ្ដល់ការអនុញ្ញាតឱ្យអយ្យការដើម្បីដាក់ជូននូវការឆ្លើយតបមួយទាក់ទងនឹងបញ្ហា"ថ្មី"ទាំងនោះ ដែលបានលើកឡើងនៅក្នុងសារណាឆ្លើយតបរបស់ចុងចោទ តែមិនឱ្យឆ្លើយទាក់ទងនឹងបញ្ហាកាលពីមុនៗដែលភាគី "គ្រាន់តែបានព្យាយាមដើម្បីឱ្យបាននិយាយជាសំដីចុងក្រោយតែប៉ុណ្ណោះ"នោះទេ[19]។

២១- ហេតុដូចនេះ នៅក្នុងរឿងក្ដីនាពេលបច្ចុប្បន្ននេះ សហព្រះរាជអាជ្ញាសូមលើកជូនជាយោបល់ថា ដោយសារមិនមានបញ្ហាថ្មីៗត្រូវបានលើកឡើងនៅក្នុងសារណាឆ្លើយតបរួម ឬក៏មិនមានការភាន់ច្រឡំជាក់ស្ដែងណាមួយខាងអង្គហេតុ និងខាងអង្គច្បាប់ដែលមាននៅក្នុងសារណាឆ្លើយតបរួមនេះនោះទេ មិនគួរអនុញ្ញាតឱ្យមេធាវីការពារក្ដីលើកឡើងនូវ"សំដីចុងក្រោយ"លើបញ្ហានានាអំពីខ្លឹមសារដែលលេចឡើងពីសំណើសុំទាំងនោះឡើយ។ បើសិនជាក្នុងមួយលើកៗមានការដាក់ជូនមកនូវការបកស្រាយខាងអង្គហេតុ ឬខាងអង្គច្បាប់ដោយភាគីណាមួយដែលខុសៗគ្នាបែបនេះ គឺវាស្មើនឹង "សេចក្ដីថ្លែងដែលខុស", "សេចក្ដីថ្លែងដែលធ្វើឱ្យយល់ច្រឡំ" ឬ "ការកំណត់បទចោទដែលខុសខាងអង្គហេតុ និងអង្គច្បាប់" ដែលធ្វើឱ្យការធ្វើយុត្តិកម្មលើសារណាឆ្លើយតបរបស់ភាគីម្ខាងទៀតត្រូវបន្តជជែកតវ៉ាគ្នាទៅលើបញ្ហាផ្សេងៗតទៅទៀតនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងដោយគ្មានកាលកំណត់នោះឡើយ។ នេះគឺច្បាស់លាស់ណាស់ថាវាជាស៊ីណារីយ៉ូដែលសេចក្ដីណែនាំអនុវត្តបានស្វែងរក ដើម្បីជៀសវាងតាមរយៈបទប្បញ្ញត្តិស្ដីពីការកម្រិតកំណត់សិទ្ធិនៅក្នុងការឆ្លើយតប។ ការដែលអនុញ្ញាតដល់មេធាវីការពារក្ដីនូវឆន្ទានុសិទ្ធិជាឯកតោភាគីមួយ ដើម្បីងាកចេញពីសេចក្ដីណែនាំអនុវត្តនោះ វាមុខជានឹងធ្វើឱ្យមានការអូសបន្លាយពេលដោយគ្មានកំណត់ និងធ្វើឱ្យមានភាពមិនប្រាកដប្រជានៅក្នុងដំណើរការរឿងក្ដី, ធ្វើឱ្យខូចដល់សិទ្ធិរបស់ភាគីនានា នៅក្នុងការដាក់សារណាលើបញ្ហាផ្សេងៗដែលស្របតាមច្បាប់ដែលស្ថិតនៅក្នុងទំនាស់ ក៏ដូចជាខូចដល់តួនាទីក្នុងការធ្វើសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងខ្លួនឯងផ្ទាល់ទៀតផង។

២២- ជាការត្រឹមត្រូវអង្គជំនុំជម្រះសាលាដំបូងគួរតែហាមឃាត់ដល់ភាគីនានា កុំឱ្យដាក់ការឆ្លើយតបទៅនឹងការឆ្លើយតបនានា ដើម្បីរក្សាឱ្យបាននូវការត្រួតពិនិត្យទៅលើដំណើរការនីតិវិធី និងដើម្បីធានាឱ្យការគ្រប់គ្រងកិច្ចការរដ្ឋបាលរបស់តុលាការប្រកបដោយភាពឆាប់រហ័ស។ តួនាទីរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការរក្សាឱ្យបាននូវការត្រួតពិនិត្យទៅលើដំណើរការនីតិវិធី ត្រូវបានគូសបញ្ជាក់យ៉ាង

[19] *ក្នុងឯកសារដែលដូចខាងលើ,* ត្រង់កថាខ័ណ្ឌទី៤ ។

ច្បាស់លាស់នៅក្នុងវិធានផ្ទៃក្នុង ដែលទាក់ទងទៅនឹងការកោះហៅសាក្សី (វិធាន៨០ស្ទួន) និងទៅនឹងការដឹកនាំសវនាការ(វិធាន៨៥) និងតាមស្មារតីនៃវិធាន២១ អាចត្រូវបានយល់ឃើញដោយសមស្របថាជាការលាតសន្ធឹងទៅដល់គ្រប់ទិដ្ឋភាពទាំងអស់នៃដំណើរការនីតិវិធី។

## III. សំណើ

២៣-អាស្រ័យដោយមូលហេតុដូចបានផ្តល់ជូនខាងលើនេះ សហព្រះរាជអាជ្ញាសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងមេត្តាចេញសេចក្តីណែនាំមួយដូចខាងក្រោមៈ

(ក) ធ្វើការបំភ្លឺថាភាគីនានាមិនត្រូវបានអនុញ្ញាតឲ្យដាក់ការឆ្លើយតបទៅនឹងសារណាឆ្លើយតបនានាដោយគ្មានការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូងនោះឡើយ។

(ខ) ធ្វើការបញ្ជាក់ថា ការអនុញ្ញាតក្នុងការដាក់ការឆ្លើយតបទៅនឹងសារណាឆ្លើយតបណាមួយតោងតែត្រូវបានដាក់នៅមុន និងផ្សេងដាច់ដោយឡែកពីការឆ្លើយតបបច្ចុប្បន្នទៅនឹងសារណាឆ្លើយតបនោះ ហើយថានៅក្នុងសំណើសុំការអនុញ្ញាតមិនត្រូវមានខ្លឹមសារនៃការឆ្លើយតបដែលបានស្នើសុំ ទៅនឹងសារណាឆ្លើយតបនោះឡើយ។

(គ) ធ្វើការកំណត់អត្តសញ្ញាណនៃកាលៈទេសៈនានា ដែលនៅក្រោមកាលៈទេសៈនោះការអនុញ្ញាតបែបនេះ ទំនងជានឹងត្រូវបានផ្តល់ឲ្យ ហើយ

(ឃ) ធ្វើការណែនាំដល់ក្រឡាបញ្ជីសូមកុំឲ្យដាក់បញ្ចូលការឆ្លើយតបទាំងនេះ ទៅក្នុងសំណុំរឿងលុះត្រាតែ និងរហូតទាល់តែការអនុញ្ញាតឲ្យដាក់ការឆ្លើយតប ត្រូវបានអនុញ្ញាតឲ្យដោយអង្គជំនុំជម្រះសាលាដំបូងជាមុនសិន៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១១ | **លោក យ៉ែត ចរិយា**<br>សហព្រះរាជអាជ្ញារង | ភ្នំពេញ | [signature] |
| | **លោក** William SMITH<br>សហព្រះរាជអាជ្ញារង | | [signature] |